ត្រូវនិយាយ
បញ្ឈប់ការរើសអើង

២០១០

# ទិវាសិទ្ធិមនុស្សអន្តរជាតិ

អបអរសាទរខួប ៦២ ឆ្នាំ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

## អបអរសាទរទិវាសិទ្ធិមនុស្ស

*សំរាប់អ្នកការពារសិទ្ធិមនុស្ស*
*ដែលធ្វើសកម្មភាព បញ្ឈប់ការរើសអើង*

**៩ ធ្នូ ម៉ោង ៦:៣០ ល្ងាច | នៅមជ្ឈមណ្ឌលបុផាណា ភ្នំពេញ** **ការដាក់ឲ្យប្រើប្រាស់ចម្រៀងសិទ្ធិមនុស្ស** សិល្បៈករ គង់ ណៃ និងគំរោងលំហារកម្ពុជា ដែលមានលាយគ្នាតន្ត្រីប្រពៃណី និងតន្ត្រីសម័យ ដើម្បីបង្កើតជាចម្រៀងសិទ្ធិមនុស្ស ។

**៩ ដល់ ១១ ធ្នូ ម៉ោង ៦:០០ ល្ងាច | នៅខេត្តបាត់ដំបងមាន** **ការដើរដង្ហែរជាក្បួន និងការសំដែងតាមផ្លូវ** ការសំដែងសៀកអំពីការរើសអើងប្រឆាំងនឹងអ្នកប្រើសារធាតុញៀនដោយក្រុមសៀក ទីនី ទីនូ ។

**១០ ធ្នូ ម៉ោង ៧:០០ ព្រឹក | ចេញដំណើរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាប់វត្តភ្នំ ឆ្ពោះទៅកាន់វត្តបទុម ភ្នំពេញ ការដើរ** **ជាក្បួនជាសាធារណៈ:** មនុស្សរាប់ពាន់នាក់ចូលរួមក្នុងការដើរដង្ហែរជាក្បួនរៀងរាល់ឆ្នាំ ដើម្បីអបអរ សាទរទិវាសិទ្ធិមនុស្សនៅក្នុងរាជធានីភ្នំពេញ ដែលបានរៀបចំឡើងដោយក្រុមការងាររៀបចំទិវាសិទ្ធិមនុស្ស។

**១០ ធ្នូ ម៉ោង ៨ - ១១ ព្រឹក |នៅពន្ធនាគារខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង** **ទិវាជំនួយផ្នែកច្បាប់** យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងការណែនាំ អំពីច្បាប់មិនយកកម្រៃដល់អ្នកជាប់ឃុំ ដោយមេធាវីសិទ្ធិមនុស្ស ។

**១០ ធ្នូ ម៉ោង ៦ : ៣០ ល្ងាច | នៅវត្តបទុមវតី ភ្នំពេញ** មានបញ្ចាំង**ខ្សែភាពយន្តខ្នាតធំ** រឿងព្រេងនិទានកម្ពុជា ចំនួនពីររឿង ។

**១០ ធ្នូ ម៉ោង ៧ ល្ងាច | នៅខេត្តកំពត** **សិទ្ធិយើង សិទ្ធិគេ** ផ្សាយផ្ទាល់ការសំដែងរឿងកំប្លែង និង កម្មវិធីសិល្បៈ សំដែងដោយសិល្បៈករខេត្ត ដោយអង្គការនិចហ្វិច (NICFEC) ។

**២៧ ធ្នូ ម៉ោង ៦:៣០ ល្ងាច | នៅមជ្ឈមណ្ឌលចេនឡា ភ្នំពេញ** ការសំដែងល្ខោននិយាយរឿង "**ព្រះអាទិត្យគ្មានពន្លឺ**" និយាយអំពីភាពក្រីក្រ និងការរើសអើង ដែលសំដែងដោយនិស្សិតសាកលវិទ្យា ល័យភូមិន្ទវិចិត្រសិល្បៈ ។

*សូមមើលឯកសារនេះ !*

**សាររបស់លោកស្រីឧត្តមស្នងការ ណាវី ភីលឡៃ** នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ
*http://www.youtube.com/watch?v=jipLAAFgvqM*

**អ្នកការពារសិទ្ធិមនុស្សនៅជុំវិញពិភពលោក** មានសំដែងក្នុងខ្សែវីដេអូនេះ
*http://www.youtube.com/watch?v=dr_hKOiXXVc*

ខ្សែភាពយន្តនៅលើ LGBT ១០ ធ្នូ ម៉ោង ៣ - ៦ ល្ងាច នៅភោជនីយដ្ឋានបៃតង (Baitong Restaurant) ផ្លូវ ៣៦០ រៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងសហគមន៍ឥន្ទធនូកម្ពុជា (Rainbow Community Kampuchea) ។

កម្មវិធីច្រើនទៀត នៃពិធីអបអរសាទរទិវាសិទ្ធិមនុស្សមានលើកម្មវិធី**ទូរទស្សន៍របស់អ្នក** **យុវវ័យថ្ងៃនេះ** (Youth Today) ឆាណែលទូរទស្សន៍របស់ខ្ញុំ (MY TV) ថ្ងៃទី១២ ធ្នូ ម៉ោង ១០ ព្រឹក កម្មវិធី **សមធម៌ ប្រចាំ**

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ

# ទិវាសិទ្ធិមនុស្សអន្តរជាតិ

**២០១០**

ត្រូវនិយាយ
បញ្ឈប់ការរើសអើង

**អំពីគោលរឿង :**

## *អ្នកការពារសិទ្ធិមនុស្សដែលធ្វើសកម្មភាព បញ្ឈប់ការរើសអើង ។*

អ្នកការពារសិទ្ធិមនុស្សកំពុងធ្វើសកម្មភាពប្រឆាំងការរើសអើង ជារឿយៗពួកគាត់ត្រូវប្រឈមនឹង ហានិភ័យខ្លាំងចំពោះខ្លួនឯងនិងក្រុមគ្រួសាររបស់ខ្លួន កំពុងត្រូវបានគេទទួលស្គាល់ និង អបអរសាទរ នៅក្នុងទិវានេះ ។

អ្នកការពារសិទ្ធិមនុស្សទាំងឡាយ ប្រកាសប្រឆាំងការរំលោភបំពានផ្សេងៗ រាប់ទាំង ការរើសអើង ការ ផាត់ចេញ ការគាបសង្កត់ និងអំពើហឹង្សា។ ពួកគាត់តស៊ូមតិដើម្បីយុត្តិធម៌និងស្វែងរកការការពារជន រងគ្រោះដោយការរំលោភសិទ្ធិមនុស្ស។ ពួកគាត់ទាមទារឲ្យអ្នកប្រព្រឹត្តល្មើសទទួលខុសត្រូវ និង ទាមទារឲ្យមានតម្លាភាពក្នុងសកម្មភាពរបស់រដ្ឋាភិបាល។ ក្នុងការអនុវត្តន៍ការងារនេះ ជារឿយៗ ពួកគាត់ត្រូវប្រឈមនឹងហានិភ័យចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពគ្រួសាររបស់ខ្លួន ។ អ្នកការពារសិទ្ធិមនុស្សខ្លះមានឈ្មោះល្បី ប៉ុន្តែអ្នកការពារសិទ្ធិមនុស្សភាគច្រើនមិនមានឈ្មោះល្បីទេ។ ពួកគាត់កំពុងធ្វើសកម្មភាពគ្រប់ទិសទីលើពិភពលោក ទាំងសកម្មភាពជាបុគ្គលម្នាក់ៗ និងទាំងសកម្មភាពជាក្រុម នៅក្នុងសហគមន៍មូលដ្ឋាន ក្នុងនយោបាយជាតិ និងនយោបាយអន្តរជាតិ ។

ទិវាសិទ្ធិមនុស្ស ១០ ធ្នូ ២០១០ គូសបញ្ជាក់ និង លើកកំពស់សមិទ្ធិផលដែលអ្នកការពារសិទ្ធិមនុស្ស គ្រប់រូបសំរេចបាន ហើយទិវានេះគូសបញ្ជាក់ជាថ្មីនូវការទទួលខុសត្រូវធំជាងគេ ដែលរដ្ឋាភិបាលទាំង ឡាយត្រូវតែមានលទ្ធភាព និង ការពារតួនាទីរបស់ខ្លួន ។ ទិវានេះ មានបំណងផងដែរ ដើម្បីជំរុញអ្នកការពារសិទ្ធិមនុស្សជំនាន់ក្រោយឲ្យប្រកាស និងចាត់វិធានការ បញ្ឈប់ការរើសអើងគ្រប់រូបភាព នៅ ពេលណា និងនៅទីណាដែលមានបញ្ហានេះកើតឡើង ។ រឿងនេះមិនបញ្ចប់នៅបន្ទាប់ពីទិវាសិទ្ធិ មនុស្ស ១០ ធ្នូ ២០១០ នេះទេ ។ ការផ្តោតលើការងារ របស់អ្នកការពារសិទ្ធិមនុស្សនឹងបន្តធ្វើនៅ ឆ្នាំ២០១១ ទាំងមូល ។



*នៅក្នុងឆ្នាំ២០០៩ ប្រជាជនរាប់ពាន់នាក់បានចូលរួមក្នុងការដើរដង្ហែរជាក្បួនជាសាធារណៈ ក្នុងពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ។*

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ